# ការសម្ភាសន៍របស់អ្នកមីងទុំ ទេវី

### កៈ អ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណារិទ្ធ    ខៈ អ្នកត្រូវគេសម្ភាសន៍ឈ្មោះទុំ ទេវី

## ពត៌មានសង្ខេបរបស់អ្នកមីងសំ អូន

សព្វថ្ងៃនេះអ្នកមីងទុំ ទេវី មានអាយុ៥៤ឆ្នាំហើយ គាត់មានស្រុកកំណើតនៅខេត្តសៀមរាប គាត់មានបងប្អូនចំនួន៥នាក់ ស្រី៣ ប្រុស២ ហើយគាត់ជាកូនពៅគេក្នុងគ្រួសារ។ កាលពីសម័យប៉ុល ពតអ្នកមីងទើបតែចាប់កំណើតបន្ទាប់ពីប៉ុល ពតបានសម្លាប់បងប្រុសទី២របស់គាត់។ ក្រោយចប់សម័យប៉ុល ពតគាត់ត្រូវបានម្ដាយគាត់នាំទៅកាន់ជាយដែនប្រទេសថៃតាមផ្ដាំរបស់ពាក់ឪពុកគាត់។

កៈ បាទជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់មីងដែលបានឲ្យខ្ញុំសម្ភាសន៍ពីប្រវិត្តរបស់មីង ហើយការសម្ភាសន៍ណឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថាព្រីហាំយ៉ង់ដែលនៅឯសហរដ្ឋអាមេរិក។ បាទ គោលបំណងរបស់សាកលវិទ្យាល័យគឺចង់សម្ភាសន៍ប្រវិត្តប្រជាជនខ្មែរ ដើម្បីរក្សារទុកប្រវិត្តប្រជាជនខ្មែរដើម្បីឲ្យកូនចៅជំនាន់ក្រោយរបស់អ្នកមីងអាចស្គាល់ពីប្រវិត្តរបស់ជីដូនជីតាហើយរៀនអំពីប្រវិត្តរបស់ពួកគាត់ណាមីងណា បាទហើយចឹងនៅពេលដែលខ្ញុំសម្ភាសន៍មីងចប់ ខ្ញុំនឹងដាក់ការសម្ភាសន៍របស់មីងណឹងនៅក្នុងវេបសាយរបស់សាលាដែលមានឈ្មោះថា www.cambodianoralhistoryproject.byu.edu ណាមីង ចឹងតើមីងយល់ព្រមឲ្យខ្ញុំដាក់ សម្ភាសន៍របស់មីងចូលទៅក្នុងវេបសាយរបស់សាលាទេមីង?

ខៈ យល់ព្រម។

កៈ បាទសម្រាប់ថ្ងៃខែដែលខ្ញុំសម្ភាសន៍មីងនេះគឺនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ហើយការសម្ភាសន៍នេះធ្វើឡើងតាមរយៈទូរស័ព្ទដែលមីងនៅឯភូមិក្រាំងអង្គ្រង សង្កាត់ក្រាំងធ្នង់ ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ ហើយខ្ញុំនេះនៅឯភូមិធ្លកអណ្ដូង សង្កាត់ស្លរក្រាម ក្រុងសៀមរាប ខេត្តសៀមរាប បាទ អញ្ចឹងខ្ញុំចង់សួរថាតើមីងមានឈ្មោះពេញឈ្មោះអ្វីដែរមីង?

ខៈ ឈ្មោះពេញឈ្មោះទុំ ទេវី។

កៈ ឈ្មោះទុំ ទេវី មែនទេមីង?

ខ៖ ចាស។

ក៖ បាទ ចុះមីងមានឈ្មោះហៅក្រៅទេនៅក្មេងអី?

ខ៖ អត់មានផង។

ក៖ ចុះមកដល់ឆ្នាំនេះអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយមីង?

ខ៖ កាលពីក្មេងៗ ចាស់ៗជូនកាលគេហៅមីក្រញ៉ាញ់ មីខ្មៅអីចឹងទៅ តាមតែគាត់ហៅទៅ។

ក៖ បាទមីង ចុះមកដល់ឆ្នាំនេះអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយមីង?

ខ៖ អាយុ៤៦ឆ្នាំ

ក៖ បាទ ចុះមីងនៅឆ្នាំថ្ងៃខែកំណើតមីងបានទេមីង?

ខ៖ ថ្ងៃ១៧ ខែ៦ ឆ្នាំ១៩៧៧។

ក៖ អរ ចឹងមីងកើតកំឡុងពេលដែលប៉ុល ពតម៉ងអ្នកមីងណោ?

ខ៖ ចាស។

ក៖ បាទ ចុះមីងមានចាំឆ្នាំខ្មែរទេមីង?

ខ៖ អត់ចាំផងឆ្នាំខ្មែរមិនដឹងថាឆ្នាំផងម៉ាក់  ចាំតែថ្ងៃម៉ាក់ប្រាប់ថ្ងៃសុក្រ តែមិនដឹងថ្ងៃអី មិនដឹងថាឆ្នាំអី។

ក៖ បាទ ចឹងមីងមានស្រុកកំណើតនៅឯណាដែរមីង?

ខ៖ នៅស្រុកកំណើតម៉ាក់ប្រាប់ថានៅសៀមរាបប៉ុន្តែថាកើត កើតនៅកណ្តាលទន្លេងកំពុងឃ្លាំងនោះ។

ក៖ បាទ ចុះអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខ៖ បងប្អូនទាំងអស់មាន៥នាក់ ប៉ុន្តែស្លាប់១នាក់។

ក៖ បាទ ហើយអ្នកមីងជាកូនទីប៉ុន្មានដែរអ្នកមីង?

ខ៖ កូនទី៥។

ក៖ កូនពៅ?

ខ៖ ចាស។

ក៖ បាទ ចឹងអ្នកមីងអាចជួយរៀបរាប់ប្រាប់ឈ្មោះបងប្អូនរបស់អ្នកមីងបានទេ? តាំងពីបងគេរហូតដល់អ្នកមីងចឹងអ្នកមីង?

ខ៖ បងគេឈ្មោះទុំ សារ៉ុន បងទី២ដឹងតែឈ្មោះផាត់។

ក៖ ផាត់?

ខ៖ ចាស ប៉ុន្តែគាត់ស្លាប់ហើយ។

ក៖ បាទមីង។

ខ៖ អត់បានឃើញមុខ បងទី៣ឈ្មោះទុំ សម្បុល បងស្រីទី៤ឈ្មោះ ទុំ សុផានី។

ក៖ បាទ បន្ទាប់មកអ្នកមីងម៉ង?

ខ៖ ចាស។

ក៖ បាទមីង អរអញ្ចឹងអ្នកមីងនៅចងចាំសាច់រឿងអ្វីខ្លះដែរពេលអ្នកមីងនៅក្មេងៗ ពេលដែលចេញពីប៉ុល ពត មកណឹងអ្នកមីងប្រហែលជាអាយុ ៣ ៤ឆ្នាំមែនទេអ្នកមីង?

ខ៖ ប្រហែលជា៣ ៤ឆ្នាំតែអត់ចាំអីដឹងតែធំដឹងក្តី ចាំបានដឹងនៅជំរុំ។

ក៖ បាទនៅជុំរុំ

ខ៖ ចាំបានពីជុំរុំតាទុំ តាទុំនៅចាំអាណឹងចាប់ផ្តើមចាំបានខ្លះៗហើយ រត់ពីជុំរុំមួយទៅជុំរុំមួយអីចឹងណា ពេលគេបាញ់គ្នាចឹងទៅរត់ពីកន្លែងមួយទៅកន្លែងមួយ ចេញពីតាទុំមកមកនៅដារិឧទៀតមក ចេញពីដារីឧមកនៅសាយប៊ីណឹងបានយូរ គេបាញ់ដែរប៉ុន្តែគ្រាន់តែយើងវាទៅជិតដល់ព្រំដែនថៃមែនទែនហើយណាអាណឹងយើងមើលឃើញថៃមួយចំហៀងខ្មែរមួយចំហៀងហើយ បើនៅតាទុំតាអីយើងនៅតូចដឹងតែគេបាញ់ ម៉ាក់ដឹកដៃទៅពុកអៀវអីចឹងរត់ទៅ យើងអត់ដឹងថាម៉េចអីម៉េចទេណឹងនៅតូចពេក។

ក៖ បាទមីង អរចឹងនៅតាទុំ នៅដារិឧ ហើយនិងនៅសាយប៊ី ទឹកដីខ្មែរមែនទេមីង?

ខ៖ អាណឹងទឹកដីខ្មែរតើ នៅសាយប៊ីណឹងអាណឹងគៀកថៃមែនទែនហើយអាណឹងគេជីក គេជីកដីទំនប់ចឹងណាឡើងទៅលើទំនប់ចឹងទៅមួយចំហៀងប្រទេសថៃ មួចំហៀង
យើងនៅ តែនៅតាទុំអាណឹងដីខ្មែរយើងតើប៉ុន្តែយើងរត់រហូតចឹងទៅ ពេលគេបាញ់គ្នាទៅបាញ់តែរហូតចឹង ខ្មែរក្រហមប៉ះជាមួយប៉ាវ៉ាបាញ់ជាមួយប៉ាវ៉ាទៅ ប៉ះជាមួយទាហានរដ្ឋកម្ពុជាគេបាញ់ណឹងទៀតទៅយើងចេះតែរត់ទៅប្រជាពលរដ្ឋ។

ក៖ បាទចុះពេលណាបានអ្នកមីងទៅដល់ខាវដាងដែរអ្នកមីង?

ខ៖ ខាវដាងណឹង ចេញពីខាវដាងមកណឹងបានទៅដល់តាទុំអីវិនណឹង ប៉ុន្តែកាលណឹងមីងនៅតូច មីងអត់ចាំទេ ចង់និយាយថាចាំដឹងក្តីត្រឹមតាទុំ ស្រុកតាទុំម៉ង តាទុំមក ដារីឧ អូរស្មាច់អីចឹងទៅណា អាណឹងចាំបើពីខាវដាងអត់ចាំទេ ខាវដាងមកស្គាល់វិញពេលគេដឹកយើងមកស្រុក

ខ្មែរវិញនោះ គេឲ្យទៅដេកនៅខាវដាងណឹង៣ ៤យប់ អាណឹងបានស្គាល់ខាវដាងវិញបើពេលយើងរត់ទៅមីងនៅតូចអត់ចាំទេ។

ក៖ បាទមីង។

ខ៖ ពេលយើងមាតុភូមិនិវត្តន៍មកវិញអាណឹង គេទៅដាក់ដេកខាវដាងណឹង ប៉ុន្មានប្រហែលមួយអាទិត្យដែរ មួយអាទិត្យ ឬ៥ថ្ងៃទេកាលណឹង។

ក៖ ចុះមីងនៅចាំទេការរស់នៅជុំរុំណឹងមានទិដ្ឋាភាពបែបណាឬក៏ រាល់ថ្ងៃណឹងមីងធ្វើអីខ្លះដែរចឹងណា?

ខ៖ នៅជុំរុំមានអីរត់តែគ្រាប់ និងអង្គរសហាប្រជាជាតិគេចែកអង្ករ ចែកម្ហូប ចែកម្ហារអីឲ្យយើងហូបចឹងណា ប៉ុន្តែគ្រាន់តែវាមិនពិបាកដូចជំនាន់អាពត វាស្រួលលឺសូវតែចាស់ៗគាត់និយាយថាជំនាន់ប៉ុល ពតវាពិបាក ប៉ុន្តែពួកមីងនៅជុំរុំនោះជុំរុំសម្តេចឪ សម្តេចឪណឹង គេមើលថៃយើងបានល្អ តែវាខ្វះខាតត្រង់ពេលអត់ទឹកហូប ៣នាក់បងទៅរែកឆ្ងាយណាស់ ទម្រាំបានទឹកមួយធុងៗមកផ្ទះទុកហូបពេលខែអស់ទឹក ប៉ុន្តែជួនកាលទៅក៏អង្គការសហាប្រជាជាតិគេយកទឹកម៉ាស៊ីនទៅចែកគេអីយើងដែរប៉ុន្តែទោះចែកក៏អត់គ្រប់ដែរបើប្រជាពលរដ្ឋច្រើនហើយចឹងប៉ុន្តែធម្មតាស្រុកមានសង្គ្រាមវាមិនដែលបានស្រួលទេ។

ក៖ បាទមីង។

ខ៖ ចាស ដល់ពេលបាននៅស្រួលមែនទែន ដឹងថាស្រួលម៉ងអាណឹងដល់ជុំរុំសាយប៊ីហើយណឹងលែងមានគេបាញ់គេបោះអីហើយអាណឹងនៅស្ងប់ស្រួល។

ក៖ ប៉ុន្តែអ្ន?កមីងនៅជុំរុំណឹងប្រហែលប៉ុន្មានឆ្នាំដែរអ្នកមីងមានចាំទេ? នៅតាមជុំរុំរហូតណឹងណា

ខ៖ មកដល់មីងចេញពីស្រុកខ្មែរទៅប្រហែល២ ៣ឆ្នាំ មីងអាយុ១៤ឆ្នាំបានមកស្រុកខ្មែរវិញ។

ក៖ ចុមចឹង១០ឆ្នាំជាងនោះ? យូរណាស់?

ខ៖ ចាស នៅតាំងពីតូចទៅតាំងពីតូច២ ៣ឆ្នាំអាយុ១៣ អរ ១៤ឆ្នាំ អាយុ ១៤ ១៥ឆ្នាំបានកស្រុកខ្មែរវិញ ឆ្នាំ១៩៩២បានត្រលប់មកស្រុកខ្មែរវិញ ពេលពុកមីងស្លាប់បានប៉ុន្មានខែគេឆ្លាក់ឈ្មោះគេដឹកមកស្រុកខ្មែរវិញដឹកមកស្រុកខ្មែរក៏ដាក់ឈ្មោះមាតុភូមិនិវត្តន៍ណឹងមកនៅសៀមរាបទៅព្រោះម៉ាក់គាត់ថាស្រុកកំណើតគាត់នៅសៀមរាបនោះ យើងមកនៅសៀមរាប់ដល់ពេលមកពីសាយប៊ីវិញមកពីជុំរុំណឹងគេដឹកយើងដាក់ចូលជុំរុំខាវដាងឲ្យដេកនៅណឹងដូចជាមីងភ្លេចហើយយូរហើយ មិនដឹង៥ថ្ងៃ ឬក៏៣ថ្ងៃទេកាលណឹងប៉ុន្តែយើងអត់បានដើរទៅណាទេយកមកដាក់នៅមណ្ឌលណឹង គេធ្វើរបងព័ទ្ធយើងនៅជើងភ្នំនៅមណ្ឌលណឹងណា អត់បានចេញដើរ

ទៅណាណីទេនៅតែក្នុងមណ្ឌលណឹងទេប៉ុន្មានថ្ងៃណឹងទម្រាំគេយកឡានពីខាវដាងណឹងមកដឹកយើងយកមកនៅសៀមរាប។

កៈ បាទ ចុះនៅជុំរុំណឹងអ្នកមីងមានបាន បានរៀនបានអីទេអ្នកមីងកាលណឹង?

ខៈ នៅជុំរុំទៅដល់សាយប៊ីអាណឹងបានរៀន ប៉ុន្តែរៀនអត់បានថ្នាក់ច្រើនដែររៀនបានដល់ថ្នាក់ទី៤ ទី៤ ទី៥ ធ្វើមាតុភូមិនិវត្តន៍មកស្រុកខ្មែរមកអត់បានរៀនទេមកដល់ស្រុកខ្មែរណឹងនៅផ្ទះមើលម៉ាក់ឈឺ មើលក្មួយ បងៗគេមកអត់ជុំគ្នានោះ គេចេញធ្វើការអត់នៅតែម៉ាក់គាត់ឈឺគាត់អីចឹងនៅក្មួយ២ ៣នាក់ ៣ ៤នាក់ ៤នាក់ មុំ អាឡិច អារិន ស្រីនាងនៅ៤នាក់ណឹង ហើយម៉ាក់គាត់ឈឺហើយនៅសៀមរាបដីអាគេចែកឲ្យមុនដំបូងណឹងមានទាន់ល្អអីសុទ្ធតែព្រៃ សុទ្ធតែចោរប្លន់យប់ឡើងស្វាត់ដែរម្តុំណឹង។

កៈ ចែកដីណឹង ចែកដីដែលនៅធ្លកអណ្តូងណឹងមែនមីង?

ខៈ ណឹងហើយ ណឹងហើយ ដីធ្លកអណ្តូងណឹងគេចែកឲ្យទទឹង២០ បណ្តោយ៤០មួយគ្រួសារ គេចិញ្ចឹមយើងប៉ុន្មានខែរដែរដូចជាកន្លះឆ្នាំដែរបានគេផ្តាច់របបពេលយើងមកពីជុំរុំវិញ។

កៈ ចឹងអ្នកមីងកាលណឹងមាន នៅជុំរុំណឹងគេបង្រៀនអក្សរខ្មែរ ឬក៏មានបង្រៀនអង់គ្លេស ឬក៏បង្រៀនថៃអីទេមីង?

ខៈ គេបង្រៀនតើ គេបង្រៀន អង់គ្លេស ថៃ ខ្មែរអីគ្រប់មុខណឹងណា ប៉ុន្តែយើងរៀនអត់ចេះរៀនចេះបានប៉ុណ្ណាប៉ុណ្ណឹង បានត្រឹមស្តាប់ថៃបានអីបានអង់គ្លេសរៀនម៉េចក៏រៀនមិនចេះនិងគេដែរ

កៈ ម៉េចបានអត់ចេះចឹងមីងអង់គ្លេស?

ខៈ អត់ដឹង រៀនម៉េចក៏អត់ចេះដែរពេលរៀនគ្រូវាយរហូត បងបង្រៀនផងក៏វាយអីក៏វាយនៅតែអត់ចេះ។

កៈ បាទអ្នកមីង ចឹងសព្វថ្ងៃបងប្អូនអ្នកមីងរស់នៅខាងណាខ្លះដែរអ្នកមីង?

ខៈ ពាល់ថ្ងៃបងប្អូននៅភ្នំពេញមួយ នៅកំពង់ស្ពឺមួយ នៅសៀមរាបមួយ នៅខ្ញុំនៅភ្នំពេញដែរ នៅភ្នំពេញ២ នៅកំពង់ស្ពឺមួយ នៅសៀមរាបមួយ ។

កៈ បាទអ្នកមីង ចឹងអ្នកមីងអាចជួយរៀបរាប់ប្រាប់បន្តិចបានទេថាអនុស្សាវរីយ៍អ្វីខ្លះដែរអ្នកមីងមានជាមួយបងប្អូនដែលមិនអាចបំភ្លេចបាន? កាលពីក្មេងៗអីទាំងសប្បាយ ទាំងកម្សត់ចឹងណាមីង?

ខៈ អនុស្សាវរីយ៍ជាមួយបងប្អូនមានតែនៅជុំរុំណឹងហើយ បងប្អូនអត់ដែលទៅណាមានអីហូបហូបជុំគ្នាទៅ ត្រីខ ត្រីខ ស្អីមានអីហូបណឹងទៅកម្សត់ម្តងដែរពីនាក់បង គេឲ្យទៅរៀនអត់ទៅរៀនទេនាំគ្នាទៅទូលសណ្តែកបណ្តុះលក់ វ៉ុនគេដាក់គេវាយត្រលប់ត្រលឹន  គេឲ្យរៀនឯងទៅ

ទូលសណ្ដែកបណ្ដុះលក់ នាំគ្នាលក់សណ្ដែកបណ្ដុះណឹងនៅតាទុំចាំបានថានៅតាទុំ ឃើញបងរកតែឯងហាត់ពេកប៉ុន្តែនៅជុំវុំបានបងៗគេរកស៊ីចិញ្ចឹមដែរបងទី១ ទី៣គេផ្សារណាត់អីចឹងគាត់ធំៗជាងយើងចឹងគាត់ទិញអង្ករយកទៅលក់ដល់ចំណោញមកគេចែកទៅ យើងនៅផ្ទះមើលកូនឲ្យគេទៅ គេចែកលុយចែកកាក់ឲ្យចាយហូបនំហូបអីចឹងទៅណា កម្សត់មានតែនៅជុំវុំណឹងឯងកម្សត់មានអីកម្សត់ជាងនៅណឹងទៀត បើមកដល់ភ្នំពេញនេះចាប់ផ្ដើមរៀងធូរតិចវិញ បានបងធូរធារទៅយើងប្អូនក៏ធូរតិចដែរ។

ក៖ បាទអ្នកមីង ចឹងមានន័យថាអ្នកមីងមកនៅសៀមរាបប៉ុន្មានឆ្នាំដែរបានទៅភ្នំពេញវិញអ្នកមីង?

ខ៖ ខ្ញុំមកដល់សៀមរាប៩២ នៅបានតែប៉ុន្មានឆ្នាំណឹង៩២ ៩៣ បោះឆ្នោតហើយខ្មែរក្រហមនៅតែវាយពេក ៩៤ ៩៥បងយកមកនៅភ្នំពេញរហូតក៏អត់បានទៅសៀមរាបវិញទៅបានតែទៅលេងមួយភ្លែតៗអីចឹង។

ក៖ បាទអ្នកមីង។

ខ៖ បើបោះឆ្នោតហើយ៩៣នៅតែខ្មែរក្រហមចូលវាយណឹងនៅសៀមរាប ងាកចូលបាញ់ ងាកចូលវាយ ងាកចូលវាយនៅណឹងហើយម៉ាក់ឈឺផងហើយបង បងស្រីមីងបង្អស់គាត់ទៅធ្វើការនៅព្រំដែននោះ ហើយបងប្រុសធ្វើនៅភ្នំពេញនៅតែមីងនិងបងស្រីមីងមួយទៀតនៅសៀមរាបអញ្ចឹងងាកៗខ្មែរក្រហមនៅតែចូលវាយនៅសុទ្ធតែស្រីៗបងក៏យកមកភ្នំពេញទាំងអស់គ្នាមកក៏អត់បានទៅវិញទៅនៅភ្នំពេញណឹងជាប់ទៅ បានមានប្ដីមានកូននៅភ្នំពេញណឹងទៅ។

ក៖ បាទ ចុះម្ដាយអ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ម្ដាយមីងឈ្មោះឃឹម សាវ៉ាត់ ឪពុកមីងឈ្មោះភឹម ទុំ។

ក៖ ភឹម ទុំ?

ខ៖ ចាស ឈ្មោះភឹម ទុំ ម៉ាក់ឈ្មោះឃឹម សាវ៉ាត់។

ក៖ បាទចុះអ្នកមីងដឹងទេថាពួកគាត់ទាំងពីរនាក់ណឹងមានស្រុកកំណើតនៅឯណាដែរមីង?

ខ៖ ម៉ាក់អ្នកស្រុកសៀមរាប ពុកលឺសូរម៉ាក់ថាអ្នកស្រុកកំពង់ឆ្នាំង ប៉ុន្តែអត់ដឹងថាស្រុកកំណើតគាត់នៅកំពង់ឆ្នាំងឬក៏ម៉េចប៉ុនគ្រាន់ថានៅកំពង់ឆ្នាំងប៉ុន្តែពុកនៅនឹងភ្នំក្រោមណឹង ប៉ុន្តែថាស្រុកកំណើតគាត់នៅកំពង់ឆ្នាំងប៉ុន្តែគាត់នៅនិងភ្នំក្រោមទេ មិនដឹងជាម្ដាយឪពុកយាយតាមីងរបស់គាត់មកនៅភ្នំក្រោមម៉េចអីម៉េច មីងអត់ដឹងដែរ។

ក៖ បាទ។

ខ៖ ព្រោះអីកាលដែលពុកស្លាប់មីងអាយុ១៣ឆ្នាំ។

ក៖ បាទ ចុះអ្នកមីងមានស្គាល់ថ្ងៃខែឆ្នាំកំណើតរបស់ម្ដាយអ្នកមីងទេ?

ខ៖ ខែឆ្នាំថ្ងៃកំណើតម៉ាក់អត់ស្គាល់ ពុកក៏អត់ស្គាល់ដែរ។

ក៖ ចុះអ្នកមីងចាំទេកាលដែលឪពុក និងម្ដាយរបស់អ្នកមីងខូចណឹងគាត់អាយុប្រហែលប៉ុន្មានដែរអ្នកមីង?

ខ៖ បើម៉ាក់ដឹងថាម៉ាក់ពេលម៉ាក់ស្លាប់អាយុ៦៥ឆ្នាំ ប៉ុន្តែពុកស្លាប់ពី៩២ ពុកអាយុគាត់ប្រហែល៦០ជាងដែរ ដូចជា៦២ មិនដឹង៦២ ឬក៏៦៥ទេដូចមានតែ២ណឹងដែរលឺស្ទូរម៉ាក់និយាយ ព្រោះកាលណឹងយើងទើបតែអាយុ១២ ១៣ឆ្នាំនៅក្មេងដែរអត់បានដឹងថាពុកអាយុប៉ុន្មានអីស្លាប់ចឹងណា ដឹងថាគាត់ស្លាប់នៅឆ្នាំ១៩៩២។

ក៖ បាទអ្នកមីង ចុះម្ដាយរបស់អ្នកមីងគាត់ជាមនុស្សបែបណាដែរអ្នកមីង? គាត់ជាមនុស្សកាចឬក៏ស្លូតដែរអ្នកមីង?

ខ៖ ម៉ាក់កាចក៏កាច ស្រួលក៏ស្រួលត្រូវរំពាត់ញឹកក៏ត្រូវ កាចម៉ាក់កាចណាស់។

ក៖ លឺថាវាយម៉ាក់អ៊ុំរហូត? សុទ្ធតែអង្រែអី?

ខ៖ វាយសុទ្ធតែកូនអង្រែហោះរ មីងធ្លាប់ត្រូវម្ដងដែរនៅសៀមរាបណឹងមុនមកភ្នំពេញ និងអាបង្កង់ផ្ទះប៉ុនៗករដៃណឹងដែរ ខ្វកៗ កាលនៅពីតូចចាំបានម៉ាក់វាយរត់ចេញផ្លោះតាមបង្អួចផ្លោះតាមបង្អួចដេញតាមវាយយើងទាល់តែបាន ម៉ាក់ខ្ញុំកាច។

ក៖ បាទ។

ខ៖ បើពុកកាចដែរតែគាត់អត់ចេះវាយចេះតែជេរ អត់ដែលឃើញពុកវាយទេបើថាពីតូចគាត់វាយយើង យើងអត់ដឹងក្ដីអីអត់ដឹងទេ ប៉ុន្តែដឹងថាស្គាល់មុខគាត់ថាគាត់ពុកមកអត់ដែលវាយមួយដៃអីមិនដែលទេ។

ក៖ បាទ ចុះអ្នកមីងមានសាច់រឿង ឬក៏អនុស្សាវរីយ៍អ្វីខ្លះដែរដែលអ្នកមីងនៅចងចាំជាមួយម្ដាយរហូតដល់សព្វថ្ងៃណឹងដែលមិនអាចបំភ្លេចបាន?

ខ៖ អនុស្សាវរីយ៍ចងចាំជាមួយម៉ាក់មានច្រើន តាំងពីពេលម៉ាក់ឈឺនៅកំដរម៉ាក់នៅសៀមរាបមានអីព្រលឹមឡើងដឹងតែអាំងត្រីខ្ទាងហូបជាមួយអំបុក យើងរែកទឹកស្រោចដំណាំទៅ គាត់អង្គុយសើចទៅ សើចផងជេរផងទៅ នៅសៀមរាបសប្បាយយើងអត់ប៉ុន្តែដឹងតែសប្បាយពេលដែលនៅភ្នំពេញក៏នៅតែសប្បាយវាអត់ស្ទូរដូចយើងសាមញ្ញានៅសៀមរាបណា អនុស្សាវរីយ៍នៅសៀមរាបជាមួយម៉ាក់ពេលដែលត្រជាក់អាណឹងចាប់ផ្ដើមនឹកគាត់ហើយ ខែត្រជាក់ចឹងព្រលឹមឡើងម៉ោង៥ដឹងតែយើងបង្កាត់គល់ឈើដុតឲ្យគាត់អាំងទៅគាត់អង្គុយហូបត្រីខ្ទាងជាមួយអំបុកយើងរែកទឹកស្រោចដំណាំទៅ គាត់ចេះតែប្រាប់ឲ្យដាំទៅពេលមានប្ដីមាន

កូន កូនធំឡើងផ្លែឈើណឹងបានកូនស៊ីហើយមែនដូចគាត់និយាយមែន ឥឡូវកូនធំៗដំណាំក៏បានផលហើយ បានផ្លែស្វាយអីកូនឡើងដើមឈើបានបាត់ហើយ។

ក៖ បាទចុះអ្នកមីងចាំទេថាកាលណឹងម្ដាយអ្នកមីងប្រកបការងារអ្វីដែរដើម្បីចិញ្ចឹមជីវិត?

ខ៖ គាត់ម៉ាក់តាំងពីមីងធំដឹងក្ដីអត់ឃើញម៉ាក់ធ្វើអីផងណឹងគាត់នៅផ្ទះណឹងមើលតែចៅព្រោះអីបងស្រីខ្ញុំទី១ និងទី៣ ទី៣ណឹងបើគិតទៅទី៤តែបងប្រុសខ្ញុំទី២ស្លាប់ហើយណា បងស្រីខ្ញុំទាំងពីរណឹងគាត់អ្នករកស៊ីទៅ ហើយម៉ាក់ខ្ញុំនិងខ្ញុំណឹងមើលក្មួយ មើលកូនឲ្យគាត់ ចុះពុកគាត់ឈឺនោះដល់ពេលចឹងម៉ាក់គាត់មានទៅរកស៊ីអីកើតគាត់នៅតែផ្ទះណឹងមើលតែចៅទៅកូនអ្នករក។

ក៖ បាទមីង ចុះឪពុកមីងវិញគាត់ប្រកបការងារអ្វីដែរដើម្បីចិញ្ចឹមជីវិតដែរមីង កាលពីមីងនៅក្មេងៗអី?

ខ៖ ពុកកាលខ្ញុំនៅពីក្មេងពេលគាត់អត់ទាន់ស្លាប់គាត់បើកឡានពេទ្យ បើកឡានទាហាន ទាហានពេទ្យណា គាត់បើកឡានទាហានពេទ្យចុះគាត់ទាហាននោះ គាត់ទាហានប៉ុន្តែគាត់បើកឡានពេទ្យ បើគេបាញ់គ្នាចឹងមានអ្នកត្រូវរបួសចឹងដឹងចឹងទៅ មីងទៅជាមួយគាត់ដែរចឹងដឹកទាំងឡានៗមកទៅមានដាច់ដៃដាច់ជើង។

ក៖ ចុះអ្នកមីងមានអនុស្សាវរីយ៍អីខ្លះដែរជាមួយឪពុកដែរមីង?

ខ៖ មាន មានតើជាមួយពុក ពុកបើកឡានទៅដឹកអ្នកត្រូវគ្រាប់ក៏ទៅជាមួយដែរ ឪពុកខានមកផ្ទះ២ ៣ថ្ងៃចឹងទៅឈឺនឹកទាល់តែពុកត្រលប់មកវិញបានជា ចឹងពេលពុកទៅដឹកគេត្រូវគ្រាប់ក៏ជិះទៅជាមួយពុកអត់ដែលទៅ ព្រោះអីដោយសារអីពុកមិនដែលវាយ ម៉ាក់វាយច្រើននោះ។

ក៖ បាទចឹងតាមពុកជាង។

ខ៖ នៅជាមួយពុកជាង ពុកអត់ដែលវាយដែលអីនោះដល់ពេលម៉ាក់វាយអត់ចង់នៅទេ ពេលពុកទៅធ្វើការបើកាលនៅតាទុំចាំដល់គេបាញ់គ្នាដល់ពុកទៅដឹកគេទៅដែរ អាណាដាច់ដៃដាច់ជើងកំណាត់ៗម៉េចក៏ឃើញដែរ ដល់ពេលពុកចាប់ផ្ដើមឈឺខ្លាំងគាត់ឈប់ ដល់ពេលទៅដល់សាយប៊ីគាត់ឈប់ធ្វើហើយ ណឹងគាត់ឈប់ធ្វើការហើយគាត់ចាប់ផ្ដើមហត់ខ្លាំងហើយ ណឹងដឹងក្ដីឃើញពុកហត់ ណឹងធ្វើអីលែងកើតហើយគាត់នៅតែផ្ទះហូបថ្នាំ ហូបបានប៉ុន្មានឆ្នាំគាត់ស្លាប់ទៅ។

ក៖ គាត់ស្លាប់ដោយសារជំងឺមីងហី?

ខ៖ ចាស គាត់កើតហ៊ីត គាត់កើតហ៊ីតថាទៅស្រុកខ្មែរណឹងទៅ គេមានថ្នាំអរទៅជាយដែនណាដឹងទៅពីស្រុកខ្មែរយើង យើងរត់ទៅណឹងលឺថាមានថ្នាំព្យាបាទជំងឺហ៊ីតនាំគ្នាទៅណឹងដល់ពេលទៅហើយណឹងមានថ្នាំអីព្យាបាទ អត់ដដែលណឹង។

ក៖ ចុះបើនៅបាញ់គ្នា បាទអ្នកមីង ចុះអ្នកមីងនៅចងចាំជីដូនជីតាបានទេអ្នកមីង?

ខ៖ ស្គាល់មីងអត់ស្គាល់ជីដូនជីតា ដឹងតែតាគាត់មេឃុំនៅវត្តពោធិ៍ណឹងគេហៅមេឃុំឡឹកមេឃុំឡឹក ហើយយាយឈ្មោះយាយយ័ន្តដឹងតែប៉ុណ្ណឹង បើយាយតាខាងពុកអត់ដឹងម៉ង។

ក៖ អរគាត់នៅឆ្ងាយនៅកំពង់ឆ្នាំង?

ខ៖ ចាស អត់ដឹង។

ក៖ បាទ ចុះពេលអ្នកមីងកើតមកណឹងអ្នកមីងកើតទាន់យាយតាទេអ្នកមីង?

ខ៖ អត់ទាន់ផងបើមីងកើតជំនាន់អាពតគេជម្លៀស លឺសូរម៉ាក់ថាគេជម្លៀសទៅនៅកំពង់ឃ្លាំងនៅកណ្តាលទន្លេនោះណឹង ហើយបងស្រីទី១ណឹងក៏បែកដែរ មីងនៅតែជាមួយបងប្រុសទី៣និងបងស្រីទី៤រាល់ថ្ងៃណឹង អាណឹងនៅជាមួយគ្នាបើបងស្រីទី១គេជម្លៀសទៅបាត់ហើយដល់បងប្រុសទី២ណឹងគេយកទៅសម្លាប់ចោលហើយបានម៉ាក់មានមីង ទំងន់មីង ចឹងគេសម្លាប់បងប្រុសទី២ស្លាប់ហើយបានមីងកើត ហើយកើតណឹងកើតកណ្តាលទន្លេទៀតនៅនិងផែ។

ក៖ បាទអ្នកមីង ចុះឪពុកម្តាយអ្នកមីងមានធ្លាប់និយាយប្រាប់ប្រវិត្តអីខ្លះដែរទាក់ទងនិងពួកគាត់អីធ្លាប់ប្រាប់មីងខ្លះទេ។

ខ៖ ចាស?

ក៖ ឪពុកម្តាយអ្នកមីងមានធ្លាប់ប្រាប់អ្នកមីងពីសម័យប៉ុល ពត ឬក៏ប្រវិត្តរបស់គាត់កាលពីគាត់នៅក្រមុំ កម្លោះអីប្រាប់មីងទេ?

ខ៖ គាត់អត់ដែលលឺសូរនិយាយពីអីទេ និយាយតែពីរឿងគាត់និយាយពីរឿងនៅជំនាន់ប៉ុល ពតអីចឹងពិបាក ប៉ុន្តែគ្រាន់តែម៉ាក់ថាគាត់អត់សូវពិបាកដោយសារបងប្រុសមីងណឹងមានមិត្តៗគេស្រលាញ់ចឹងអីចឹងគេរអែងឲ្យរបស់គាត់ហូបអីចឹងណា ដល់ពេលយើងនៅផែចឹងស្រួលមានចានមានអីហូបបាយត្រឹមត្រូវពេលហូបហើយចងខ្សែទម្លាក់ចូលក្នុងទឹកទៅ គាត់ថាពេលហូបយើងស្រាវយកមកហូបវិញ ដូចយើងចងសំណាញ់ទម្លាក់ចូលក្នុងទឹកទៅ ទម្លាក់ត្រាំទឹកទៅពេលយើងត្រូវការហូបយើងយកមក ពេលមានរបរអីហូបចងទម្លាក់ក្នុងទឹកទៅ លាក់គេអត់ឲ្យគេដឹងណា បើថាកន្លែងគេនៅផ្សេងគេពិបាកអីចឹងណា ប៉ុន្តែកន្លែងដែលម៉ាក់ខ្ញុំនៅថាគាត់អត់សូវពិបាកទេ ដោយសារយើងនៅលើផែលើទឹកអីចឹងរកត្រីរកនេះរកនោះបានហូបអីចឹង មិត្តៗគេឲ្យអីចឹងទៅយើងហូបលាក់លៀមអីខ្លះទៅ អាណឹងលឺសូរតែម៉ាក់ប្រាប់ដែរអត់ដឹង

ដែរ ព្រោះពេលដែលកើតហើយបាន២ ៣ឆ្នាំរត់ចេះទៅជុំរុំបាត់ហើយ គេយកគេចាប់ពុកដាក់គុកហើយគេចាប់បងប្រុសខ្ញុំដាក់គុកទៀតក៏ពុកឲ្យដល់ពេលគេលែងបងប្រុសខ្ញុំពុកឲ្យម៉ាក់នាំកូនទៅលិចមុនទៅ ចាំគាត់ចេញគាត់ទៅតាមក្រោយចឹងណា ណឹងគាត់ប្រាប់ដឹងប្រវិត្តដែលយើងបានរត់ទៅជុំរុំណឹងចឹងព្រោះអីគេយកបងទី២ទៅសម្លាប់ចោមមុនហើយបើពីសង្គមពួកគាត់សុទ្ធតែទាហាននោះ ចឹងគេចាប់ គេទើបតែដឹងថាបងប្រុសបងទី២ណឹងទាហានសក្តិ១សក្តិ២ចឹងណាគេយកទៅកសាងបាត់ទៅ ហើយចឹងដល់ពេលគេចាប់បងប្រុសមួយទៀតហើយនិងពុកទៀតចុះពុកទាហានដែរនោះ ចឹងក៏ពុកឲ្យម៉ាក់ណឹងយកបងប្រុសខ្ញុំ ខ្ញុំ និងបងស្រីខ្ញុំណឹងរត់ទៅលិចទៅក្រែងលោបានរស់ ទៅបានគាត់គ្នាចេញទៅដល់លិចទៅជុំរុំទៅអីនឹងគេណឹងទៅ។

ក៖ បាទមីង ចឹងមូលហេតុចឹងទេបានៗទៅជុំរុំនោះ។

ខ៖ ចាស កុំអីអត់បានស្គាល់ជុំរុំនិងគេទេ។

ក៖ បាទ ចឹងអ្នកមីងមានបងប្អូន ឬក៏សាច់ញាតិណាដែលរស់នៅក្រៅប្រទេសអត់ទេអ្នកមីង?

ខ៖ មាន មានតើមានបងម៉ាក់ខ្ញុំប៉ុន្តែប្រហែល១ឆ្នាំ ២ឆ្នាំមុខគាត់ស្លាប់ហើយ មិនសូវដែលបានទាក់ទងគ្នាដែរព្រោះអីតាំងពីបើនៅជុំរុំនោះទាក់ទងគ្នាដែរគេរអែងសរសេរសំបុត្រសរសេរអីមកសួរសុខទុក្ខយើងចឹងដែរណា ប៉ុន្តែតាំងពីយើងមាតុភូមិនិវត្តន៍ចូលស្រុកខ្មែរមកក៏ដាច់ដំណឹងគ្នាក៏ប៉ុន្តែប្រហែលជា១ឆ្នាំ ២ឆ្នាំមុននេះគេមកលេងម្តងដែរ ណឹងត្រូវជាបងប្អូនជីដូនមួយ។

ក៖ បាទចុះអ្នកមីងនៅចាំឈ្មោះពួកគាត់ទេហើយនៅប្រទេសណាដែរ?

ខ៖ គេនៅអាមេរិកមិនដឹងនៅឯណាអត់ដឹងនៅរដ្ឋណាអីរដ្ឋណាអត់ដឹងដែរ ណឹងទាល់តែបងស្រីមីងបងគេបង្ហស់ណឹងបានគាត់ដឹង គាត់ស្គាល់ព្រោះអីគាត់ធ្លាប់ពួកណឹងមកអីចឹងណាដែលបងមកលេងថ្ងៃមុនណឹងដឹងតែឈ្មោះប្រុស ឈ្មោះប្រុសណឹងហើយតែមួយទៀតមិនដឹងឈ្មោះអីទេឈ្មោះវាវែងពេកអត់បានចាំ។

ក៖ បាទមីង ចុះស្វាមីរបស់អ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ឈ្មោះសារិន នីរ៉ាត់។

ក៖ បាទអ្នកមីង ចុះអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយនិងស្វាមីនៅឆ្នាំណាដែរ ហើយនៅឯណាដែរ?

ខ៖ នៅរៀបការជាមួយគាត់នៅភ្នំពេញ នៅ១០០ខ្នងឆ្នាំ១៩៩៧។

កៈ ចុះអាពាហ៍ពិពាហ៍ណឹងត្រូវបានរៀបចំឡើងដោយឪពុកម្ដាយ ឬក៏ដោយចិត្តខ្លួនឯងដែរកាលណឹង?

ខៈ ម៉ែឪអ្នករៀបការឲ្យប៉ុន្តែស្រលាញ់គ្នាខ្លួនឯង។

កៈ បាទអ្នកមីង ចុះអ្នកមីងអាចប្រាប់បន្តិចបានទេថា ពេលវេលាដំបូងដែលជួបគ្នាជាមួយលោកពូណឹង ជួបនៅឯណាហើយម៉េចបានចាប់ផ្ដើមមានចិត្តស្រលាញ់គ្នាដែរចឹងអ្នកមីង?

ខៈ មានជួបនៅឯណា ជួបនៅផ្ទះណឹងជិះម៉ូតូកាត់មុខផ្ទះរាល់ថ្ងៃទៅ គេជិះម៉ូតូកាត់មុខផ្ទះយើងរាល់ថ្ងៃ ឃើញរាល់ថ្ងៃទៅ ដើរលេងជាមួយគ្នាទៅ ស្គាល់គ្នាទៅស្រលាញ់គ្នាទៅ។

កៈ បាទអ្នកមីង ចុះកាលណឹងអ្នកមីងមានចាំទេថាបានថ្លៃជំនូនអីប៉ុន្មានដែរពីខាងស្វាមីដែរអ្នកមីង?

ខៈ បានថ្លៃផ្ទះ១០០០ ថ្លៃផ្ទះ១០០០តែប៉ុណ្ណឹងហើយមានអីទៀត។

កៈ អត់មានបានគោ មានអីទេមីង?

ខៈ អត់ទេ អត់មានទេ មានតែគេយកថ្លៃផ្ទះឲ្យយើង១០០០ហើយនិង ពេលការដូចខាងគេរ៉ិចអន្សមរ៉ិចអីទៅចឹង ផ្លែឈើយើងអ្នកទិញគេរ៉ិចអន្សមទៅ។

កៈ បាទអ្នកមីង ចុះកាលណឹងអ្នកមីង ហេតុអីក៏អ្នកមីងជ្រើសរើសរៀបការជាមួយលោកពូដែរកាលណឹងអ្នកមីង? កាលណឹងអ្នកមីងមូលហេតុអីបានជ្រើសរើសរៀបការជាមួយលោកពូដែរចឹងណា អ្នកមីងមានមូលហេតុអីដែរ ឬក៏ម៉េចដែរចឹងណា?

ខៈ មានមូលហេតុអី មូលហេតុស្រលាញ់គ្នាណឹងហើយ។

កៈ បាទអ្នកមីង អញ្ចឹងមានន័យថាបន្ទាប់ពីអ្នកមីងចេញពីជុំរុំមកណឹងអ្នកមីងរៀនដល់ថ្នាក់ទី៤ណឹងអ្នកមីងឈប់ចូលរៀនទៀតហើយ ទោះបីមកនៅសៀមរាបក៏ដោយមែនទេអ្នកមីង?

ខៈ មកដល់សៀមរាបណឹងអត់បានរៀនទៀតទេព្រោះអីក្មួយ មីស្រីនោះបងស្រីខ្ញុំគេឲ្យកូនគេទៅរៀននៅខេត្ត ចឹងនៅអាកូនគាត់២ និងក្មួយស្រីខ្ញុំមួយទៀតណឹង និងម៉ាក់ខ្ញុំណឹង ខ្ញុំអ្នកមើល ចឹងមានបានទៅរៀនឯណាទៀតអត់បានទៅរៀនទៀត រៀនតអីទៀត ទម្រាំយើងមកទម្រាំយើងធ្វើផ្ទះបាននៅ ក៏មិនបានភ្លាមៗប្រហែលមួយឆ្នាំបាត់ហើយ ទម្រាំបានផ្ទះនៅធ្វើអីហើយកាប់ព្រៃកាប់អី ដល់ពេលចឹងម៉ាក់គាត់ឈឺផងយើងនៅផ្ទះមើលម៉ាក់ហើយនិងក្មួយៗបងស្រីខ្ញុំមួយនៅសៀមរាបណឹងគេធ្វើការគេលក់ទឹកកក លក់គ្រឿងកំប៉ុងលក់អីទៅយើងនៅផ្ទះមើលក្មួយ មើលបាយ មើលម្ហូបកាប់អុសរកអីទៅ អត់បានរៀនទៀតទេ។

កៈ បាទអ្នកមីង ចុះមកដល់សព្វថ្ងៃនេះអ្នកមីងចេះអាន និងចេះសរសេរអក្សរខ្មែរតើហ៎អ្នកមីង?

ខ៖ រាល់ថ្ងៃអានបាន សរសេរបាន ស្តាប់គេនិយាយបាន។

ក៖ បាទអ្នកមីង ចុះអ្នកមីងមានមិត្តភិក្តដែលស្និតស្នាលធំធាត់មកជាមួយគ្នាតាំងពីតូចដល់ឥឡូវមានទេអ្នកមីង?

ខ៖ មានមួយ ប៉ុន្តែរកវាអត់ឃើញសោះពីបែកគ្នាពីជុំរុំមក ទៅតាមរកវានៅបាត់ដំបងម្តងដែរតែរកអត់ឃើញអត់ដឹងវាទៅនៅឯណា មិនដឹងមាតុភូមិនិវត្តន៍នៅឯណា។

ក៖ គាត់ឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ឈ្មោះមីឈឺន រៀនជាមួយគ្នាតាំងពីថ្នាក់ទី១រហូតទាល់តែមាតុភូមិនិវត្តន៍មកបានបែកគ្នាពេលឥឡូវណឹងទៅរកវាមុនណឹងពី៩០ជាងទៅរកម្តងដែររកអត់ឃើញមិនដឹងនៅឯណា។

ក៖ បាទអ្នកមីង ចុះអ្នកមីងមានអនុស្សាវរីយ៍អ្វីខ្លះដែរជាមួយមិត្តស្និតស្នាលរបស់អ្នកមីងណឹង?

ខ៖ មានអនុស្សាវរីយ៍ លួចនាំគ្នាងូតទឹកអូរមកវិញម៉ែវាយ ស្អែកលួចងូតទៀតមកវិញម៉ែវាយទៀត ហើយនិងល្ងាចឡើងចេញពីរៀននាំគ្នាទៅវត្តរែកទឹកដាក់ពាងឲ្យលោកឲ្យយាយជីទុកប្រើ តែ២នាក់ពួកម៉ាក់ណឹងឯងមានហូបអត់ហូបអីតែ២នាក់ណឹងប៉ុន្តែរកវាដែរតែអត់ឃើញមិនដឹងវានៅឯណា មិនដឹងម៉េចអីម៉េចវាមានតែ២នាក់បងប្អូនដែរម៉ែវាមេម៉ាយគ្នាអត់ដែរ តាំងពីណឹងមកមិនដែលមានមិត្តភិក្តពួកម៉ាក់អីទៀត។

ក៖ បាទ អញ្ចឹងតាំងពីក្មេងមកដល់សព្វថ្ងៃនេះអ្នកមីងធ្លាប់ប្រកបការងារអ្វីខ្លះដើម្បីចិញ្ចឹមជីវិតនិងគ្រួសារដែរមីង?

ខ៖ មានតែធ្វើការរោងចក្រ ពីក្រមុំធ្វើការោងចក្រនិងគេដែរពេលមានប្តីឈប់ ឈប់បានកូនចូលធ្វើវិញទៀត ដល់ពេលទំងន់កូនទី២ប្តីគេឲ្យឈប់ទៀត ដល់មកកូនទី៥នេះបានចាប់ផ្តើមធ្វើវិញ ឥឡូវទើបតែឈប់បាន១ឆ្នាំជាង គ្មានធ្វើការអីក្រៅពីរោងចក្រយើងអត់ចេះអីនោះធ្វើការអីកើត។

ក៖ បាទ អញ្ចឹងអ្នកមីងអាចជួយប្រាប់បានទេថាតើក្នុងជីវិតអ្នកមីងណាមានឧបសគ្គ ឬក៏ការលំបាកណាដែលធំជាងគេបំផុតក្នុងជីវិតរបស់អ្នកមីងដែរអ្នកមីងតាំងពីក្មេងដល់ឥឡូវ?

ខ៖ ដូចមិនទាន់មានអីឲ្យធំជាងគេ លំបាកឲ្យធំជាងគេដូចមិនទាន់មាន តាំងពីក្មេងរហូតមកនៅជាមួយម៉ាក់ ដូចគ្មានអីលំបាកលំបិនឲ្យនេះ មានហូបអត់ហូបអីលើបង លើម៉ាក់អី ដល់ពេលមកមានប្តីមកក៏មិនមែនថាពិបាក វាពិបាកដែរប៉ុន្តែថាវាមិនពិបាកអីដល់ថ្នាក់អីលំបាកលំបិនអីខ្លាំងទេគ្រាន់តែ អឺធម្មតាតែមានកូនច្រើនវាខ្វះខាតអីខ្លះហើយវាមិនដែលបានគ្រប់ទេយើងវារកបានតិចចំណាយច្រើនចឹងណា បើថាឲ្យទៅលំបាកខ្លាំងអីអត់ទាន់ជួបប្រទះផង។

ក៖ បាទ ចឹងសុទ្ធតែលំបាកតិចៗទាំងអស់?

ខ៖ ចាស លំបាកមួយយើងទ្រាំបាន យើងគិតថាយើងប៉ុណ្ណឹងលំបាកពេកកូនឈឺយើងយកកូនទៅពេទ្យឃើញអ្នកដេកក្រោមស្ពានគ្នាពិបាកជាងយើងទៀត យើងពិបាកយើងមានផ្ទះដេកគ្នាពិបាកអត់ផ្ទះដេក ប៉ុន្តែយើងគិតថាយើងពិបាកហើយប៉ុណ្ណឹងតែមានបញ្ហាខ្លះវាពិបាកដែរណឹងពិបាកគិតពិបាកគិតមិនចេញអីមិនចេញដែរគ្រាន់ពេលយប់អី ម៉ោង១ ម៉ោង២ពេលកូនប្រកាច់អីយើងជិះម៉ូតូយកកូនទៅពេទ្យទៅឃើញគេដូចពិបាកជាងយើងទៀត អាណឹងចាត់ទុកថាយើងនៅកម្រិតស្រាលជាងគេ។

ក៖ បាទ អញ្ចឹងតាំងពីក្មេងមកដល់ពេលនេះតើជីវិតមីងមានការផ្លាស់ប្តូរអ្វីខ្លះដែរមីង?

ខ៖ ពីក្មេងដល់ឥឡូវផ្លាស់ប្តូរច្រើនតើ ពីក្មេងយើងដឹងតែស្រួលនៅជាមួយម៉ែជាមួយឪពេលមានប្តីមានកូនយើងទទួលខុសត្រូវលើវាទាំងអស់ ផ្លាស់ប្តូរមួយចំហៀងមេយហើយចឹង យើងមើលការខុសត្រូវវា ហាត់និយាយស្តីណែនាំសព្វគ្រប់បែបយ៉ាង ផ្លាស់ច្រើនណាស់ពីនៅជាមួយម៉ែឪដល់យើងមានប្តីមានកូន។

ក៖ បាទ អញ្ចឹងក្នុងជីវិតមីងតើអ្នកមីងគិតថាជាពេលដែលសប្បាយជាងគេក្នុងជីវិតដែរមីងតាំងពីក្មេងមកដល់ពេលនេះ?

ខ៖ សប្បាយជាងគេនៅជាមួយពុកជាមួយម៉ាក់ ពេលពុកអត់ទាន់ស្លាប់អាណឹងដូចថាយើងសប្បាយម៉ងធ្វើអីក៏បានដែរដល់ពេលពុកស្លាប់ទៅចាប់ផ្តើមអង្គុយគិតថា បើសិនជាធ្វើដូចមុនទៀតគេវាយអត់មានអ្នកជួយ ចាប់ផ្តើមផ្លាស់ប្តូរខ្លួនឯង រាងសុភាពរាបរយត្រឹមត្រូវម្តងតិចៗតាំងពីពុកស្លាប់មកអញ្ចឹងណា កាលពុកអត់ទាន់ស្លាប់ដឹងតែអត់មានខ្លាចអ្នកណាគេទេសូម្បីតែបងៗក៏អត់ខ្លាចដែរ។

ក៖ មានខ្ទង?

ខ៖ ចាស អស់ខ្ទងយប់ឡើងអង្គុយគិតប្រសិនជាធ្វើចឹងទៀតគេវាយអត់មានអ្នកជួយទេ។

ក៖ បាទអ្នកមីង ចុះកាលពីនៅក្មេងមកដល់ពេលនេះតើអ្នកមីងធ្លាប់មានក្តីស្រម៉ៃថាធំឡើងចង់ធ្វើអីអត់ទេអ្នកមីង?

ខ៖ មានក្តីស្រម៉ៃតាំងពីក្មេងមកគិតថាធំឡើងចង់ធ្វើរៀនចង់ធ្វើអ្នកការសែត ដល់ពេលរៀនអត់ដឹងឯណាឯណីក្តីស្រម៉ៃនោះវាឈប់ចោលទៅ គ្មានចង់ធ្វើអីចង់ធ្វើអ្នកការសែត។

ក៖ ចុះមូលហេតុអ្វីដែរបានជម្រុញឲ្យអ្នកមីងចាប់ចិត្តទៅលើខាងចង់ធ្វើអ្នកការសែតណឹងអ្នកមីង?

ខ៖ ឃើញអ្នកការសែតល្អយកពត៌មានពីនេះពីនោះអីចឹងទៅយើងជួយសង្គមមានច្រើន ចិត្តពីក្មេងចង់ នឹកឃើញធំឡើងរៀនចប់ប្រលងខាងចូលធ្វើអ្នកការសែតដល់ពេល យើងរៀនបាន

តែប៉ុណ្ណឹងនៅតែប៉ុណ្ណឹងមើលតែក្មួយ មើលតែចង្ក្រានមើលតែអីណឹង ក៏វាបញ្ចប់ចោលទៅអា គោលបំណងចង់ធ្វើអ្នកការសែត។

កៈ បាទ អញ្ចឹងជិតចប់ហើយអ្នកមីង ចឹងឥឡូវយើងផ្លាស់ប្តូរមកកាន់ចំណង់ចំណូលចិត្តអ្នក មីងម្តង ចឹងតើអ្នកមីងចូលចិត្តពិសារម្ហូបណាជាងគេដែរអ្នកមីងក្នុងចំណោមម្ហូបទាំងអស់ ម្ហូប ដែលចូលចិត្តជាងគេណា?

ខៈ ម្ហូបចូលចិត្តជាងគេហី?

កៈ បាទ។

ខៈ មានតែប្រហុកចញ្រ្ចាំ ហើយនិងស្លរម្ជូរ២មុខណឹង។

កៈ ចូលចិត្តជាងគេម៉ង?

ខៈ ចាស។

កៈ ចុះបើសាច់គោអីមកដូរអត់ដូរទេមីងនៃ?

ខៈ អេ សាច់គោយូរៗម្តងអីទៅ បើថាប្រហុកចញ្រ្ចាំ ចញ្រ្ចាំទុកមួយកែវៗចឹងទៅ ម្ហូបហូបបាយ បើហូបអីមិនកើតៗ សាច់គោបានតែយូរៗម្តងម្កាលទេរាល់ថ្ងៃពេកក៏ហូបមិនកើតដែរជឿមីង ទៅ?

កៈ បាទមីង ចុះម្ហូបណាវិញដែលមីងអត់ចូលចិត្តញុំ?

ខៈ អត់ចូលចិត្ត?

កៈ បាទ។

ខៈ ស្អប់ជាងគេអាឆាននោងដាក់កំពឹស សព្វថ្ងៃឲ្យតែពូមក ឆារននោងមានកំពឹសតិចអូយ មីង ហើយនិងអីគេស្លរល្ពៅ ស្លរម្ជូរល្ពៅជាមួយត្រីឆ្អើរ អូយ។

កៈ ខ្ញុំមិនដែលលឺដែរ។

ខៈ ទាំងកូន ទាំងប្តីគេចូលចិត្តណាស់ប៉ុន្តែមីងស្លរហើយ មីងសុទ្ធចិត្តចៀនពងទា ឬក៏ប្រហុក មីងចញ្រ្ចាំទុកមួយកែវណឹងឆ្អឹសមកហូបទៅ។

កៈ ចុះកាលពីនៅជំទង់ នៅក្រមុំអី អ្នកមីងចូលចិត្តស្តាប់ចម្រៀងទេមីង?

ខៈ ចូលចិត្តស្តាប់តើ ទោះចាស់ណឹងក៏នៅតែចូលចិត្តស្តាប់។

កៈ អ្នកមីងចូលចិត្តស្តាប់ចម្រៀងតារាមួយណាដែរមីង?

ខ៖ ស្តាប់តែទាំងអស់ណឹង មើលតែបទណាទំនងស្តាប់ទៅ ប៉ុន្តែបើភាគច្រើនស្តាប់តែបទថៃ មិនសូវស្តាប់ខ្មែរ។

ក៖ បាទអ្នកមីង ចុះកាលពីនៅក្រមុំអីអ្នកមីងធ្លាប់បានទៅលេងល្បែងប្រជាប្រិយអ្វីខ្លះដែរតាមវត្តតាមអីពេលចូលឆ្នាំអីម្តងៗ

ខ៖ អត់ដែលផង។

ក៖ អត់ដែលទៅលេងទេ?

ខ៖ អត់ ទៅ ទៅវត្តប៉ុន្តែទៅមើលគេតែអត់ដែលចេះលេងអីនិងគេ។

ក៖ ខ្លាចម៉ាក់វាយឬក៏ម៉េចមីង?

ខ៖ តាំងពីតូចរហូតដល់ប៉ុណ្ណេះសូម្បីតែបោះបាយបិណ្ឌទៅវត្តមើលគេបោះបាយបិណ្ឌម្តងតែអត់បានបោះទេបានតែមើលគេទេ ហើយបើគេលេងផាត់ម្សៅផាត់អីនៅវត្តណឹង អត់ចេះតាំងពីតូចអត់ដែលចេះទៅលេងនិងគេទេ បើថាទៅឈរមើលគេឆ្ងាយៗអីមើល មើលគេរាំ មើលគេរាំអកកេសមើលអីមើល ឲ្យទៅលេងនិងគេអត់ចេះ។

ក៖ អញ្ចឹងមកដល់សព្វថ្ងៃនេះអ្នកមីងមានកូន និងចៅប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ មានកូន៥។

ក៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មានដែរអ្នកមីង?

ខ៖ ប្រុស៤ ស្រី១។

ក៖ ចៅអត់ទាន់មានទេ?

ខ៖ ចៅជិតមានហើយប្រហែល១ឆ្នាំ ២ឆ្នាំអីទៀតប្រហែលជាមានហើយចៅ។

ក៖ បាទអ្នកមីង អញ្ចឹងមកដល់ចុងបញ្ចប់នេះតើអ្នកមីងមានអ្វីចង់ផ្តាំផ្ញើ ឬក៏ទូន្មានទៅកាន់កូនចៅជំនាន់ក្រោយរបស់អ្នកមីងទេថាតើពួកគេគួរតែរស់នៅបែបណា? ឬក៏ធ្វើជាមនុស្សបែបណា ឬប្រព្រឹត្តបែបណានៅក្នុងសង្គមដែរមីង?

ខ៖ មានផ្តាំផ្ញើរទៅកូនៗទៅចៅជំនាន់ក្រោយឲ្យវានៅក្នុងសង្គមគេឥឡូវធ្វើអំពើល្អ កុំទៅសេពគ្រឿងញៀនអីតែផ្តេសតែផ្តាសដើរផ្លូវណាដែលមិនត្រឹមត្រូវ ឲ្យខំប្រឹងរៀន ដើម្បីមានអនាគតឲ្យល្អនិងគេ បើសម័យឥលូវបើអត់ខំប្រឹងរៀនអត់អីទេអនាគតគ្មានអីក្រៅពីរោងចក្រទេ ហើយធ្វើការរោងចក្រមីងធ្លាប់ធ្វើហើយពិបាកណាស់ គេជេរ គេថា គេជេរ គេថា អត់ចង់ឲ្យកូនឬក៏ចៅៗណាទៅធ្វើការដូចមីងចឹងទេ ហើយឲ្យកូនធ្វើតែអំពើល្អទៅ ដើរក្នុងសង្គមគេឥលូវគេធ្វើតែអំពើល្អយើងនាំគ្នាធ្វើអំពើល្អ អ្នកណាមិនល្អកុំយកតម្រាប់តាម មានតែប៉ុណ្ណឹង។

ក៖ បាទអ្នកមីង អញ្ចឹងជាចុងបញ្ចប់នេះខ្ញុំសូមអរគុណដល់អ្នកមីងដែលបានចំណាយពេលវេលាសម្ភាសន៍ជាមួយខ្ញុំមីងណា ចឹងខ្ញុំសូមជូនពរឲ្យអ្នកមីង មានសុខភាពល្អ មានសំណាងល្អ និងមានសុភមង្គលក្នុងក្រុមគ្រួសារអ្នកមីងណា។

ខ៖ ចាស សូមឲ្យក្មួយដូចគ្នាដែរ។

ក៖ បាទណឹងហើយ អរគុណអ្នកមីង។